ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
លេខាធិការដ្ឋាន

លេខៈ ៤៦៣ គជអប/គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ[illegible] ឆ្នាំ២០១៣

# សេចក្តីជូនដំណឹង
## ស្តីពីការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៤

លេខាធិការដ្ឋាន គ.ជ.អ.ប មានកិត្តិយសសូមជម្រាបដល់អ្នកទទួលការទាំងអស់ឱ្យបានជ្រាបថា នៅខែកញ្ញា ឆ្នាំ២០១៣ខាងមុខនេះ រាជធានី ខេត្តនៅទូទាំងព្រះរាជាណាចក្រកម្ពុជានឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការ ដើម្បីដេញថ្លៃគម្រោងមូលនិធិឃុំសង្កាត់ឆ្នាំ២០១៤។ អ្នកទទួលការដែលត្រូវបានចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ មានសិទ្ធិដាក់សំណើដេញថ្លៃគម្រោងមូលនិធិឃុំសង្កាត់ នៅគ្រប់ឃុំសង្កាត់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

អ្នកទទួលការត្រូវបានបែងចែងជា០៣ប្រភេទៈ

ប្រភេទទី១ៈ អ្នកទទួលការសំណង់ទូទៅ (ការងារសំណង់អគារ និងការងារបេតុង... ។ល។)

ប្រភេទទី២ៈ អ្នកទទួលការការងារដី (ប្រឡាយ ទំនប់ ផ្លូវដីស ផ្លូវក្រាលក្រួសក្រហម... ។ល។)

ប្រភេទទី៣ៈ អ្នកទទួលការឯកទេស (អ្នកទទួលការដែលមានឧបករណ៍ និងជំនាញពិសេសសម្រាប់ការងារពិសេស ដូចជា អណ្តូងស្នប់... ។ល។)

អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេស សម្ភារៈ និងបរិក្ខារគ្រប់គ្រាន់ដូចមានបរិយាយនៅក្នុងពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ ដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំ និងត្រូវមានបទពិសោធន៍អនុវត្តគម្រោងទាក់ទងនឹងប្រភេទនីមួយៗ ដែលបានស្នើសុំយ៉ាងតិចចំនួន០២ ក្នុងអំឡុងពេល០៥ឆ្នាំចុងក្រោយ។ អនុគណៈកម្មការបុរេលក្ខណៈសម្បត្តិនឹងចុះពិនិត្យដល់ទីតាំងក្រុមហ៊ុនរបស់អ្នកទទួលការ និងវាយតម្លៃសមត្ថភាពបច្ចេកទេសដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចមានបរិយាយនៅក្នុងពាក្យស្នើសុំចុះបញ្ជី ព្រមទាំងពិនិត្យគុណភាពការងារ ភាពស្មោះត្រង់ការអនុវត្តការងារទាន់ពេលវេលា និងកិច្ចសហប្រតិបត្តិការរបស់អ្នកទទួលការជាមួយម្ចាស់គម្រោង ដោយផ្អែកលើកំណត់ត្រាកន្លងមក។ លទ្ធផលនៃការវាយតម្លៃនេះ អនុគណៈកម្មការបុរេលក្ខណៈសម្បត្តិនឹងដាក់ជូនអភិបាលរាជធានី ខេត្តដើម្បីពិនិត្យ និងសម្រេច។

អាស្រ័យហេតុនេះ បើអ្នកទទួលការណាមានបំណងចុះបញ្ជីឈ្មោះអ្នកទទួលការ សូមរួសរាន់មកដាក់ពាក្យនៅរាជធានី ខេត្តដែលខ្លួនធ្វើអាជីវកម្មអចិន្ត្រៃយ៍។ ចំពោះអ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការក្នុងឆ្នាំកន្លងមក ក៏ត្រូវដាក់ពាក្យជាថ្មីឡើងវិញដែរ។ ពាក្យសុំចុះឈ្មោះអ្នកទទួលការអាចរកបាននៅទីចាត់ការផែនការ និងវិនិយោគនៃសាលារាជធានី ខេត្ត<u>ដោយឥតគិតថ្លៃ ឬទាញយកពីគេហទំព័រ គ.ជ.អ.ប</u> (www.ncdd.gov.kh)។

ការប្រកាសជូនដំណឹងស្តីពីការដាក់ពាក្យចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ ដោយឡែកសម្រាប់រាជធានីខេត្តនីមួយៗមានបិទផ្សាយនៅលើក្តារព័ត៌មានរបស់សាលារាជធានី ខេត្តរៀងៗខ្លួន។

ជ. ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប
អនុប្រធាន

ចាន់ ដារ៉ែន